**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ ៦៨៨៥/ប្រក.ប.ស្ល/ខហប/២០២៤

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអភិវឌ្ឍ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញប្រកាសលេខ ០២១ ប្រក ប.ស្ល ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើរាល់គម្រោងអភិវឌ្ឍ សាធារណៈ និងឯកជន នៅក្នុងដំណាក់កាលការធ្វើចំណាត់ថ្នាក់គម្រោង ការកំណត់វិសាលភាពគម្រោង ការពិនិត្យ និងឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការអង្កេតតាមដានគម្រោង ព្រមទាំងមានការចូលរួមជាសាធារណៈ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធខាងក្រោយនៃប្រកាសនេះ។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគម្រោងស្នើសុំ គម្រោងមានស្រាប់ និងគម្រោងកំពុងដំណើរការ ដែលតម្រូវឱ្យមានការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ កិច្ចសន្យាការពារបរិស្ថាន។

**ប្រការ៣.-**

គម្រោងអភិវឌ្ឍដូចមានចែងក្នុងប្រការ២ខាងលើ ត្រូវដាក់ពាក្យសុំអភិវឌ្ឍគម្រោងទៅអាជ្ញាធរមានសមត្ថកិច្ច ឬ ក្រសួងសាមី និងត្រូវកំណត់ចំណាត់ថ្នាក់គម្រោង ដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ កិច្ចសន្យាការពារបរិស្ថានពីក្រសួងបរិស្ថាន។

**ប្រការ៤.-**

ក្រុមហ៊ុនទីប្រឹក្សា និងម្ចាស់គម្រោងត្រូវជូនដំណឹងមកក្រសួងបរិស្ថាន នៅពេលទទួលបានការចុះកិច្ចព្រមព្រៀងប្រគល់គម្រោង សម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

**ប្រការ៥.-**

គម្រោងអភិវឌ្ឍដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ក្នុងរយៈពេលយ៉ាងយូរ ៩០(កៅសិប)ថ្ងៃ ដាក់ជូនក្រសួងបរិស្ថាន ហើយក្រសួងបរិស្ថានពិនិត្យ ផ្តល់យោបល់ និងឯកភាព ក្នុងរយៈពេលយ៉ាងយូរ ៩០(កៅសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលទទួលបានរបាយការណ៍។

**ប្រការ៦.-**

គម្រោងអភិវឌ្ឍដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ក្នុងរយៈពេលយ៉ាងយូរ ៦០(ហុកសិប)ថ្ងៃ ដាក់ជូនក្រសួងបរិស្ថាន ហើយក្រសួងបរិស្ថានពិនិត្យ ផ្តល់យោបល់ និងឯកភាព ក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលទទួលបានរបាយការណ៍។

**ប្រការ៧.-**

គម្រោងអភិវឌ្ឍដែលតម្រូវឱ្យរៀបចំកិច្ចសន្យាការពារបរិស្ថាន ដោយភ្ជាប់ផែនការគ្រប់គ្រងបរិស្ថាន ក្រសួងបរិស្ថានពិនិត្យ ឯកភាព និងរៀបចំលិខិត និងវិញ្ញាបនបត្រឯកភាពលើកិច្ចសន្យាការពារបរិស្ថានក្នុង

រយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលក្រសួងទទួលបានពាក្យសុំពិនិត្យលើកិច្ចសន្យាការពារបរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន និងឯកសារពាក់ព័ន្ធ។

ចំពោះគម្រោងធ្វើអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច មានទំហំផ្ទៃដីមិនលើសពី ១០(ដប់)ហិកតា ពុំតម្រូវឱ្យភ្ជាប់ផែនការគ្រប់គ្រងបរិស្ថានអនុលោមតាមប្រកាសអន្តរលេខ ១៩១ ប្រក.ប.ស្ថ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច រវាងក្រសួងបរិស្ថាន និងក្រសួងរ៉ែ និងថាមពល។

**ប្រការ៨.-**

នៅក្នុងដំណើរការសិក្សា រៀបចំ ពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវមានការពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ គ្រប់ភាគីពាក់ព័ន្ធ និងអ្នកដែលទទួលរងផលប៉ះពាល់ពីគម្រោង។

**ប្រការ៩.-**

នៅក្នុងដំណើរការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ រៀបចំកិច្ចសន្យាការពារបរិស្ថាន តម្រូវឱ្យមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរងការប៉ះពាល់ និងអាជ្ញាធរភូមិ ឃុំ សង្កាត់ពាក់ព័ន្ធ។

ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ មន្ត្រីជំនាញនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ត្រូវចុះពិនិត្យទីតាំង និងពិនិត្យផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង តាមនីតិវិធី ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងបរិស្ថានពិនិត្យ និងឯកភាព។

ក្នុងករណីចាំបាច់ ដំណើរការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងត្រូវមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត មន្ទីរជំនាញពាក់ព័ន្ធ និងកិច្ចប្រជុំអន្តរក្រសួង។

**ប្រការ១០.-**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដែលបានដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់ នៅមានចំណុចខ្វះខាត នោះម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ធ្វើការកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនោះ និងបញ្ជូនរបាយការណ៍ដែលបានកែតម្រូវនោះមកក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់ឡើងវិញ ក្នុងរយៈពេលយ៉ាងយូរបំផុត ៣០(សាមសិប)ថ្ងៃ។

**ប្រការ១១.-**

ករណីម្ចាស់គម្រោងពុំគោរព និងអនុវត្តតាមប្រការ៥ ប្រការ៦ ប្រការ៧ និងប្រការ១០ ខាងលើ ក្រសួងបរិស្ថានមិនទទួលខុសត្រូវលើភាពយឺតយ៉ាវ ឬ បដិសេធលើការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន។

**ប្រការ១២.-**

ករណីក្រសួងបរិស្ថានពិនិត្យឃើញថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង បានកែសម្រួលត្រឹមត្រូវតាមការផ្តល់យោបល់របស់ក្រសួងបរិស្ថានហើយនោះ ក្រសួងបរិស្ថាននឹងរៀបចំលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ជូនក្រុមហ៊ុនម្ចាស់គម្រោង។

**ប្រការ១៣.-**

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវចូលរួមអនុវត្តន៍ជាមួយម្ចាស់គម្រោងអភិវឌ្ឍ និងតាមដានលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងកិច្ចសន្យាការពារបរិស្ថានដែលក្រសួងបរិស្ថានបានឯកភាព។

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត និងអង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦រោច ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**អ៊ាង សុផល្លែត**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៥ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ដ្យាក្រាម៖ នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ម្ចាស់គម្រោងអភិវឌ្ឍ/វិនិយោគ ដាក់ពាក្យស្នើសុំ → អាជ្ញាធរមានសមត្ថកិច្ច ឬ ក្រសួងសាមី និង/ឬរាជរដ្ឋាភិបាល

↓

ក្រសួងបរិស្ថាន

↓

**របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA)**

↓

-ក្រុមហ៊ុនទីប្រឹក្សារាយការណ៍មកក្រសួងអំពីការទទួលបានគម្រោង និងរយៈពេលសម្រាប់រៀបចំរបាយការណ៍ EIA
-ម្ចាស់គម្រោងសហការជាមួយក្រុមហ៊ុនទីប្រឹក្សារៀបចំ និងបញ្ជូនរបាយការណ៍ EIA មក ក្រសួងបរិស្ថានពិនិត្យផ្តល់យោបល់ និងសម្រេច
(រយៈពេលយ៉ាងយូរបំផុត ១៨០ថ្ងៃ)

**របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA)**

↓

-ក្រុមហ៊ុនទីប្រឹក្សារាយការណ៍មកក្រសួងអំពីការទទួលបានគម្រោង និងរយៈពេលសម្រាប់រៀបចំរបាយការណ៍ IEIA
-ម្ចាស់គម្រោងសហការជាមួយក្រុមហ៊ុនទីប្រឹក្សារៀបចំ និងបញ្ជូនរបាយការណ៍ IEIA មកក្រសួងបរិស្ថានពិនិត្យផ្តល់យោបល់ និងសម្រេច
(រយៈពេលយ៉ាងយូរបំផុត ៩០ថ្ងៃ)

**កិច្ចសន្យាការពារបរិស្ថាន**

↓

-នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** អំពីគម្រោងរៀបចំកិច្ចសន្យា
- ក្រសួងបរិស្ថានពិនិត្យ និងសម្រេចលើកិច្ចសន្យាការពារបរិស្ថាន
(៣០ថ្ងៃនៃថ្ងៃធ្វើការ)

ការចូលរួមជាសាធារណៈ:

↓

ម្ចាស់គម្រោងសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ធ្វើការកែតម្រូវលើរបាយការណ៍ EIA និង IEIA រួចបញ្ជូនមកក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់ឡើងវិញ
(រយៈពេលយ៉ាងយូរបំផុត ៣០ថ្ងៃ)

↓

រៀបចំលិខិតឯកភាព និងកិច្ចសន្យាការពារបរិស្ថានជូនក្រុមហ៊ុនម្ចាស់គម្រោង

↓

អង្កេតតាមដានការអនុវត្តរបាយការណ៍ EIA និង IEIA និងកិច្ចសន្យាការពារបរិស្ថាន ← ម្ចាស់គម្រោងអភិវឌ្ឍ/វិនិយោគ និងក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន